# NEWS RELEASE

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**ប្រទេសកម្ពុជា៖ អ្នករាយការណ៍ពិសេសអ.ស.ប មានប្រសាសន៍ថា**
**"ត្រូវតែយកសិទ្ធិមនុស្សធ្វើជាបេះដូងនៃការផ្តល់សម្បទានដី ដើម្បីផលប៉ះពាល់ជាវិជ្ជមាន"**

ភ្នំពេញ/ហ្សឺណែវ (ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២) - លោក **សុរិយា ប្រាសាទ ស៊ូប៊ែឌី** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា បានជំរុញរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមអនុវត្តប្រកបដោយតម្លាភាពថែមទៀត នៅពេលផ្តល់ និងគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត សូមត្រួតពិនិត្យមើលឲ្យកាន់តែដិតដល់លើសហគ្រាសពាណិជ្ជកម្មនានា ដែលពាក់ព័ន្ធនឹងសម្បទានដី ហើយសូមដំណើរការផ្តល់សម្បទានដីដោយមានការចូលរួមថែមទៀតពីសំណាក់បុគ្គល និងសហគមន៍នានាដែលរងផលប៉ះពាល់។

ឆ្លុះបញ្ចាំងអំពីបេសកកម្មស្វែករកការពិតរបស់លោកនៅតំបន់សម្បទានក្នុងខេត្តរតនគិរី ក្រចេះ និងស្ទឹងត្រែង លោក **ស៊ូប៊ែឌី** បានមានប្រសាសន៍ថា "នៅកំឡុងបេសកកម្ម ខ្ញុំបានជួបជាមួយបុគ្គល អ្នកភូមិ និងសហគមន៍នានា ដែលត្រូវបានប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត ហើយបានឮដោយផ្ទាល់ត្រចៀកនូវផលប៉ះពាល់ដែលមានលើជីវិតរបស់ពួកគេ។ ខ្ញុំទទួលបានសក្ខីភាពដ៏ទុក្ខសោកមួយចំនួន ហើយបានទៅមើលឃើញដោយផ្ទាល់ភ្នែកនូវផលប៉ះពាល់ដែលសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀតមានលើប្រជាពលរដ្ឋមូលដ្ឋាន ក៏ដូចជាធនធានធម្មជាតិ"។

អ្នកជំនាញការឯករាជ្យរូបនេះបានមានប្រសាសន៍ថា "ពួកគេបានពិពណ៌នាអំពីប្រព័ន្ធមួយដែលតម្លាភាពមានកំរិតទាបពន់ពេក មានន័យថាសហគមន៍ជានិច្ចកាលពុំបានដឹងថាពេលណា និងតាមរបៀបណា ដែលសម្បទានដីកំពុងត្រូវបានផ្តល់នៅក្បែរដីរបស់ពួកគាត់នោះទេ"។ "ពួកគេពុំដឹងឮច្រើនអំពីក្រុមហ៊ុន ដែលទទួលបានសម្បទានដី ក៏ដូចជាកំណត់ត្រាប្រតិបត្តិការរបស់ក្រុមហ៊ុនថាតើវាជាក្រុមហ៊ុនបរទេស ឬក្នុងស្រុក ហើយក្នុងករណីខ្លះ មិនដឹងសូម្បីតែឈ្មោះរបស់ក្រុមហ៊ុន។"

អ្នករាយការណ៍ពិសេសបានសង្កត់ធ្ងន់ថា "ការវាយតំលៃរបស់ខ្ញុំផ្ទាល់បញ្ជាក់អះអាងលើស្ថានការណ៍នេះ។" "ការទទួលបានព័ត៌មានគឺមានសារសំខាន់ខ្លាំងណាស់" លោកបានទទួលបានព័ត៌មានពីសហគមន៍នានាថា "អាជ្ញាធរ ឬក្រុមហ៊ុនកម្រនិងពិគ្រោះយោបលជាមួយពួកគាត់ប្រកបដោយអត្ថន័យណាស់ ហើយពេលខ្លះសឹងតែគ្មានតែម្តង អំពីផលប៉ះពាល់នៃសម្បទានដីលើជីវិត និងការរស់នៅរបស់ពួកគាត់។"

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

លោក **ស៊ូប៊ែឌី** បានដាក់ការយកចិត្តទុកជាពិសេសលើស្ថានការណ៍របស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ដែលចំណងផ្សាភ្ជាប់នឹងដីរបស់ពួកគាត់ ត្រូវបានគេដឹងឮ និងចងក្រងជាឯកសារយ៉ាងច្បាស់លាស់។ លោកទទួលស្គាល់កិច្ចការរបស់រាជរដ្ឋាភិបាល ដែលបានបង្កើតក្របខណ្ឌគតិយុត្តិជាក់លាក់ស្តីពីកម្មសិទ្ធិដីធ្លីសម្រាប់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ហើយបានស្វាគមន៍ចំពោះការផ្តល់កម្មសិទ្ធិដីសមូហភាពចំនួនបីជាលើកទី១ ដល់សហគមន៍ជនជាតិដើមភាគតិច។

លោកបានមានប្រសាសន៍ថា "ដរាបដល់សហគមន៍ទាំងនេះអាចទទួលបានកម្មសិទ្ធិដីធ្លីរបស់ពួកគាត់ ដីជនជាតិដើមភាគតិចគួរត្រូវបានការពារ និងធានារក្សាតាមច្បាប់ជាធរមាន" ហើយលោកបានជំរុញលើកទឹកចិត្តរដ្ឋាភិបាលសូមពន្លឿនដំណើរការផ្តល់កម្មសិទ្ធិដីធ្លីសមូហភាពផ្សេងៗទៀត។

នៅកំឡុងបេសកកម្មរយៈពេលប្រាំបីថ្ងៃរបស់លោក អ្នករាយការណ៍ពិសេសក៏បានជួបជាមួយមន្ត្រីថ្នាក់ខេត្ត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងក្រសួងរាបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍មួយចំនួនដែលធ្វើការលើវិស័យនេះផងដែរ។

អ្នករាយការណ៍ពិសេសបានស្វាគមន៍បទបញ្ជារបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ចុះថ្ងៃទី៧ ខែឧសភា ឲ្យផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចនានា និងបង្គាប់ឲ្យពិនិត្យឡើងវិញនូវរាល់សម្បទានដែលបានផ្តល់ឲ្យទាំងអស់ ដើម្បីការពារផលប្រយោជន៍របស់សហគមន៍នានា។ លោកបាននិយាយថា "វាគឺជាការបោះជំហានដ៏ប្រសើរនៅក្នុងទិសដៅត្រឹមត្រូវ។ ដូចលើកមុនៗដែរ គេត្រូវផ្តោតការយកចិត្តទុកដាក់លើការអនុវត្តនៃបទបញ្ជាថ្មីនេះ"។

លោក **ស៊ូប៊ែឌី** បានទៀតថា "វាច្បាស់លាស់ណាស់ដែលថា ប្រជាពលរកម្ពុជាទាំងអស់ចង់ឃើញកំណើនការអភិវឌ្ឍន៍សេដ្ឋកិច្ច ប៉ុន្តែការអភិវឌ្ឍន៍នេះគួរតែងតែប្រព្រឹត្តទៅក្នុងលក្ខណៈចេរភាពដោយជះផលប៉ះពាល់ជាអវិជ្ជមានតិចតួចបំផុតលើសហគមន៍នានាតាមដែលអាចធ្វើទៅបាន ទន្ទឹមនឹងនោះដែរ ត្រូវលើកកំពស់សិទ្ធិមនុស្សរបស់បុគ្គលទាំងឡាយដែលពាក់ព័ន្ធ"។

អ្នករាយការណ៍ក៏បានលើកឡើងផងដែរថា "ខ្ញុំសង្ឃឹមថាដំណើរបោះឆ្នោតនាពេលខាងមុខនឹងប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ ដែលនឹងបន្តពង្រឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា" ហើយលោកបានបួងសួងដល់ប្រជាពលរដ្ឋកម្ពុជា និងគណៈបក្សនយោបាយទាំងអស់ ដែលចូលរួមក្នុងការបោះឆ្នោតឃុំសង្កាត់ខាងមុខ "ឲ្យទទួលបានសំណាងល្អ"។

លោក **ស៊ូប៊ែឌី** នឹងដាក់ការរកឃើញ សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់លោក ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប នៅខែកញ្ញា ឆ្នាំ២០១២ ខាងមុខនេះ។

(*) អានសេចក្តីថ្លែងការណ៍ទាំងស្រុងរបស់អ្នករាយការណ៍ពិសេស៖

ចប់

*លោកសាស្ត្រាចារ្យ **សុរិយា ប្រាសាទ ស៊ូប៊ែឌី** ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នក រាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយ ការណ៍ពិសេស លោកមិនចំណុះ រដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាព បុគ្គលលោកផ្ទាល់ ។ បច្ចុប្បន្នលោក គឺជាសាស្ត្រាចារ្យ ផ្នែកនីតិអន្តរជាតិ នៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*គេហទំព័រ OHCHR ប្រចាំកម្ពុជា៖*

*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និងការសួរដំណឹងផ្សេងៗ សូមទំនាក់ទំនង៖*

***នៅភ្នំពេញ៖*** កញ្ញា Zoe Latumbo, (+855 12 790 178 / zlatumbo@ohchr.org)

***នៅហ្សឺណែវ៖*** លោក Robert Vaughan (+41 22 928 9188 / rvaughan@ohchr.org)

សម្រាប់**ការសួរដំណឹង**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យអ.ស.បផ្សេងៗទៀត៖

Xabier Celaya, UN Human Rights – Media Unit (+ 41 22 917 9383 / xcelaya@ohchr.org)

UN សិទ្ធិមនុស្ស សូមតាមដានយើងនៅបណ្តាញទំនាក់ទំនងសង្គម៖

Facebook: https://www.facebook.com/unitednationshumanrights

Twitter: http://twitter.com/UNrightswire

Google+ gplus.to/unitednationshumanrights

YouTube: http://www.youtube.com/UNOHCHR

ចូលរួមជាមួយយើងដើម្បីនិយាយឲ្យលឺៗសម្រាប់សិទ្ធិមនុស្ស នៅ Rio+20, use **#RightsRio**